ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការប្រារព្ធទិវាជាតិអំណាន ១១ មីនា ២០១៩

ក្រសួងអប់រំ យុវជន និងកីឡាមានកិត្តិយសសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា៖ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង លើការអភិវឌ្ឍធនធានមនុស្ស ដើម្បីកសាងសង្គមជាតិឱ្យមានភាពរីកចម្រើនជឿនលឿន ដូចប្រទេសអភិវឌ្ឍន៍នានាលើសកលលោក។ ក្រសួងបានចាត់ទុកថា **អំណាន** ជាធាតុដ៏សំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដើម្បីឆ្លើយតបនឹងគោលដៅអប់រំជាតិ។

## ១. ហេតុអ្វីបានជា ទិវាជាតិអំណាន ប្រារព្ធនៅថ្ងៃ ១១ មីនា

រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីទិវាជាតិអំណាន និងបានកំណត់យកថ្ងៃ ទី ១១ ខែ មីនា ដើម្បីប្រារព្ធទិវានេះជារៀងរាល់ឆ្នាំ។ ការសម្រេចជ្រើសរើសយកថ្ងៃទី ១១ ខែ មីនានេះ ដោយសារជាថ្ងៃខែកំណើតរបស់ **សម្តេចព្រះសង្ឃរាជ ជួន ណាត** និងមានបំណងរំឭកដល់វីរភាពរបស់សម្តេចព្រះសង្ឃរាជ ដែលបានខិតខំតស៊ូពុះពារការពារមរតកវប្បធម៌អក្សរសាស្ត្រខ្មែរពីអាណានិគមនិយមបារាំង។

## ២. គោលបំណងនៃការប្រារព្ធទិវាជាតិអំណាន

ការប្រារព្ធទិវាជាតិអំណានមានគោលបំណង ៖ ១) កៀគរអ្នកចូលរួមគាំទ្រកាន់តែច្រើនកុះករនិងអធិកអធមពីគ្រប់អ្នកពាក់ព័ន្ធនិងមហាជនទូទៅ ២) បណ្តុះទម្លាប់អាន ជំរុញវប្បធម៌

អាន លើកកម្ពស់សមត្ថភាពអាន និងការតែងនិពន្ធ សំដៅរួមចំណែកការពារនិងពង្រឹងវប្បធម៌អរិយធម៌ខ្មែរដល់សិស្ស និស្សិត មន្ត្រីរាជការ ប្រជាជនគ្រប់រូបក្នុងប្រទេសកម្ពុជា ៣) លើកកម្ពស់ រក្សាគុណតម្លៃកេរ្តិ៍ដំណែលរបស់មនុស្សជាតិ ៤) សម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលជានាគុណភាពអប់រំប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

## ៣. ប្រធានបទសម្រាប់ឆ្នាំ ២០១៩

មកទល់ឆ្នាំ ២០១៩ នេះ ទិវាជាតិអំណានត្រូវបានប្រារព្ធឡើង ៤ លើកមកហើយ ដែលក្នុងឆ្នាំនីមួយៗមានប្រធានបទដូចខាងក្រោម៖

- ឆ្នាំ ២០១៦ ៖ ប្រធានបទ "**បណ្ដុះទម្លាប់អានជំរុញវប្បធម៌អាន**"
- ឆ្នាំ ២០១៧ ៖ ប្រធានបទ "**អានដើម្បីភាពសុខដុមនៃជីវិត**"
- ឆ្នាំ ២០១៨ ៖ ប្រធានបទ "**អំណានជាកំណប់វិជ្ជាមហាសាល**"
- ឆ្នាំ ២០១៩ ៖ ប្រធានបទ "**ការអានបណ្ដុះវប្បធម៌ការសិក្សាពេញមួយជីវិត**"

ប្រធានបទឆ្នាំនេះ សមស្របនឹង ពាក្យស្លោកមួយចំនួនដូចខាងក្រោម៖

- អំណានជាឃ្លាំងចំណេះ វិជ្ជាជាឃ្លាំងប្រាជ្ញា
- អំណានគឺជាមូលដ្ឋានគ្រឹះនៃចំណេះដឹង
- អំណានតាមបច្ចេកវិទ្យា ជាវិជ្ជាសម្បទាសតវត្សទី២១
- អំណានជាប្រភពនៃចំណេះដឹង
- អំណានជាមាគ៌ាឆ្ពោះទៅរកភាពជោគជ័យក្នុងជីវិត
- អានច្រើនចម្រើនប្រាជ្ញា គតិជ្រះថ្លា ចំណេះដឹងមហាសាល
- សៀវភៅជាឃ្លាំង អំណានជាយាន្ត ឈានទៅយកចំណេះដឹង
- ឪពុកម្ដាយអាន កូនអាន យើងទាំងអស់គ្នាអាន
- អានច្រើន សរសេរច្រើន កើនចំណេះ
- អំណាន ដើម្បីការអភិវឌ្ឍ

ប្រធានបទនេះរួមចំណែកធ្វើឲ្យសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលធានាគុណភាពអប់រំប្រកបដោយបរិយាបន្ន សមធម៌ និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និងស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ។

## ៤. សកម្មភាពនានាក្នុងការប្រារព្ធទិវាជាតិអំណាន

- ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំការប្រកួតប្រជែងអានអត្ថបទ ស្មូតកំណាព្យ តែងនិពន្ធដើម្បីទទួល **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** និងសកម្មភាពអំណានផ្សេងៗនៅតាមគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន

- ការប្រកួតប្រជែងបកស្រាយអត្ថបទអក្សរសិល្ប៍ក្រោមប្រធានបទ "តថភាពសង្គមតាមរយៈស្នាដៃអក្សរសិល្ប៍រឿងកុលាបប៉ៃលិន និងផ្កាស្រពោន" ក្នុងចំណោមបុគ្គលិកអប់រំ

- ការរៀបចំស្តង់ចតរូប ការតាំងពិព័រណ៍សៀវភៅរយៈពេល ៣ ថ្ងៃ ពីថ្ងៃទី ៩ ដល់ ១១ ខែ មីនា ឆ្នាំ ២០១៩ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

- ពិធីអបអរសាទរទិវាជាតិអំណាន ១១ មីនា លើកទី ៤ ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ព្រមទាំងកម្មវិធីជួបជាមួយវាគ្មិនល្បីៗដែលមកធ្វើបាឋកថារយៈពេលពេញមួយថ្ងៃ។

អាស្រ័យដូចបានជម្រាបជូនខាងលើ **គណៈកម្មការរៀបចំទិវាជាតិអំណាន** សង្ឃឹមថាបងប្អូនសាធារណៈជនទាំងអស់នឹងចូលរួមគាំទ្រ និងផ្សព្វផ្សាយការប្រារព្ធទិវាជាតិអំណាន ១១ មីនា ២០១៩ នេះឲ្យបានកាន់តែទូលំទូលាយ។

ថ្ងៃអង្គារ ៧ រោច ខែ មាឃ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៩